GC LiFE

# ការពារខ្លួន ជាក្រុម



**តើអ្វីទៅជា “គម្រោងការពារខ្លួន” ជាក្រុម ?**

“គម្រោងការពារខ្លួន” ជាក្រុម គឺជាគម្រោងធានារ៉ាប់រងដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់ សហគ្រាស ស្ថាប័ន អង្គការ និងក្រុមគ្រួសាររបស់អ្នក។  គម្រោងនេះផ្តល់នូវការការពារ 24/7 សម្រាប់បុគ្គលិក និងសមាជិកគ្រួសាររបស់អ្នកមិនថាពួកគេនៅកន្លែងណាក៏ដោយ។

**តើអ្នកណាសាកសមនឹង “គម្រោងការពារខ្លួន” ជាក្រុម?**

សហគ្រាស ស្ថាប័ន អង្គការ និងក្រុមគ្រួសារណាដែលចង់ផ្តល់ការការពារដល់បុគ្គលិក ឬសមាជិកគ្រួសាររបស់ពួកគាត់។



### ហេតុអ្វីបានជាចាំបាច់ជ្រើសរើស“គម្រោងការពារខ្លួន” ជាក្រុម?

“គម្រោងការពារខ្លួន” ជាក្រុម គឺជាគម្រោងធានារ៉ាប់រងមានភាពបត់បែន ដែលលោកអ្នកអាចជ្រើសរើសការការពារដ៏ល្អបំផុតទៅតាមតម្រូវការរបស់លោកអ្នក។ សម្រាប់គម្រោងនេះ ក្រៅពីការការពារលើមរណភាព និងពិការភាពជាអចិន្ត្រៃយ៍ បុគ្គលិក និងសមាជិកគ្រួសាររបស់លោកអ្នកអាចបន្ថែមការការពារសម្រាប់ការចំណាយលើការពិគ្រោះជំងឺក្រៅ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងអត្ថប្រយោជន៍ផ្សេងទៀត រួមមានប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ និងប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម។ល។



## លក្ខណៈនៃផលិតផល

| | |
|---|---|
| ចំនួនអ្នកត្រូវបានធានារ៉ាប់រង | 3នាក់ឡើង |
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 18 – 65ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |
| វិធីសាស្រ្តបង់បុព្វលាភ | បង់ម្តងផ្តាច់ |

## អត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រង

| អត្ថប្រយោជន៍ធានារ៉ាប់រង | គម្រោង Platinum<br>ទឹកប្រាក់សំណង | គម្រោង Gold<br>ទឹកប្រាក់សំណង | គម្រោង Silver<br>ទឹកប្រាក់សំណង |
|---|---|---|---|
| ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុក្នុងរយៈពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃកើតហេតុនោះ នឹងទទួលបាន៖ | $20,000 | $10,000 | $5,000 |
| ក្រោយរយៈពេលរង់ចាំ ៩០ថ្ងៃត្រូវបានបញ្ចប់ ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយសារជំងឺនឹងទទួលបាន៖ | $4,000 | $2,000 | $1,000 |
| បុព្វលាភធានារ៉ាប់រង | $68 | $35 | $18 |

> “ បុព្វលាភទាប ទឹកប្រាក់សំណងខ្ពស់ ការពារបុគ្គលិក និង សមាជិកគ្រួសារ របស់អ្នកយ៉ាងកក់ក្តៅពេញ ៣៦៥ថ្ងៃ ”

## តើលោកអ្នកត្រូវការបន្ថែមការការពារមែនទេ?

សូមពិចារណាបន្ថែមនូវធានារ៉ាប់រងខាងក្រោម៖

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ - ការពិគ្រោះជំងឺក្រៅ

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ - ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេត - ការផ្ទេរទៅព្យាបាលនៅមន្ទីរពេទ្យក្រៅប្រទេសដោយសារស្ថានភាពធ្ងន់ធ្ងរ

## ករណីមិនធានា

**១. មរណភាព**

(១) ការធ្វើអត្តឃាត

(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លោចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

(១) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(២) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតានៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(៣) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។
(៤) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីពនានា។

៣. មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ
(១) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្ត ចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។
(២) អ្នកត្រូវបានធានារ៉ាប់រងបានដឹងថាខ្លួនមានបញ្ហារាងកាយមិនប្រក្រតី មានជំងឺ ឬរបួសមុនពេលចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែអ្នកត្រូវបានធានារ៉ាប់រងមិនបានជូនដំណឹងដល់ក្រុមហ៊ុនឡើយ។
(៣) ការមានគភ៌ ការសម្រាលកូន ការរលូតកូន ឬផលវិបាកណាមួយកើតចេញពីកត្តាទាំងអស់នេះ។
(៤) មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍បណ្តាលមកពីរបួសបង្កដោយគ្រោះថ្នាក់ជាយថាហេតុ និងដែលកើតឡើងក្នុងអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃគ្រោះថ្នាក់ជាយថាហេតុ។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ខ្លះៗប៉ុណ្ណោះ។ សម្រាប់ករណីមិនធានាលម្អិតទាំងស្រុង សូមពិនិត្យមើល ខ និងលក្ខខណ្ឌធានារ៉ាប់រង។

# ចំណាំ៖

ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នា
ដោយសង្ខេប។
សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង
រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា
និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា
សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។

**ទំនាក់ទំនងមកកាន់យើងខ្ញុំ**


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វ៉ែនផាក ផ្ទះលេខ A១២ ផ្លូវR៨
ភូមិ ១ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ